# សំណុំសកម្មភាពអប្បបរមាម៉ូឌុលទី 10

## ( MPA 10)

# ការវាយតម្លៃខ្លួនឯង



មិថុនា ២០០៩

# មាតិកា


| | | |
|---|---|---|
| ១ | ការវាយតម្លៃខ្លួនឯងសំរាប់បុគ្គលិកកម្មវិធីជាតិអាហារូបត្ថម្ភ | 4 |
| ២ | ឧបករណ៏វាយតម្លៃខ្លួនឯងសំរាប់អ្នកអភិបាលថ្នាក់ខេត្ត | 10 |
| ៣ | ឧបករណ៏វាយតម្លៃខ្លួនឯងសំរាប់អ្នកអភិបាលស្រុកប្រតិបត្តិ | 15 |
| ៤ | ឧបករណ៏វាយតម្លៃខ្លួនឯងសំរាប់បុគ្គលិកមណ្ឌលសុខភាព | 20 |
| ៥ | ឧបករណ៏វាយតម្លៃខ្លួនឯងសំរាប់អ្នកស្ម័គ្រចិត្តភូមិ | 28 |

១

# ឧបករណ៍វាយតម្លៃខ្លួនឯងសំរាប់បុគ្គលិកកម្មវិធីជាតិអាហារូបត្ថម្ភ

ឧបករណ៍វាយតម្លៃខ្លួនឯងនេះនឹងត្រូវបានយកមកប្រើប្រាស់ដោយមន្ត្រីកម្មវិធីជាតិអាហារូបត្ថម្ភរៀងរាល់បីខែម្តងដើម្បីវាយតម្លៃស្នាដៃរបស់បុគ្គលិកកម្មវិធីជាតិអាហារូបត្ថម្ភ។

## របៀបប្រើប្រាស់ឧបករណ៍នេះ

### ១- មន្ត្រីគ្រប់គ្រងកម្មវិធីជាតិអាហារូបត្ថម្ភ បង្ហាញពីឧបករណ៍វាយតម្លៃ

ឧបរណ៍វាយតម្លៃនេះផ្តល់ឱកាសដល់មន្ត្រីកម្មវិធីជាតិអាហារូបត្ថម្ភ និងបុគ្គលិកកម្មវិធីជាតិអាហារូបត្ថម្ភដើម្បីកំណត់រកនូវសកម្មភាពដែលមានដំណើរការល្អ និងសកម្មភាពដែលចាំបាច់ត្រូវពង្រឹងបន្ថែម។ ឧបករណ៍នេះក៏ផ្តល់ឱកាសឱ្យក្រុមកម្មវិធីជាតិអាហារូបត្ថម្ភធ្វើការជាមួយគ្នាក្នុងការកំណត់រកនូវវិធីដើម្បីពង្រឹងសកម្មភាព និងឯកភាពលើសកម្មភាពអនុវត្តរបស់ខ្លួន។

បុគ្គលិកកម្មវិធីជាតិអាហារូបត្ថម្ភ និងធ្វើការជាលក្ខណៈបុគ្គលក្នុងការបំពេញទំរង់នេះ ហើយបន្ទាប់មកប្រើទំរង់នេះដើម្បីធ្វើការពិភាក្សាជាមួយមន្ត្រីគ្រប់គ្រងកម្មវិធីជាតិអាហារូបត្ថម្ភ។

### ២- មន្ត្រីគ្រប់គ្រងកម្មវិធីជាតិអាហារូបត្ថម្ភ ធ្វើការបង្ហាញ និងពន្យល់ពីទំរង់វាយតម្លៃខ្លួនឯងនេះ។

### ផ្តល់ទំរង់នេះឱ្យបុគ្គលិកកម្មវិធីជាតិអាហារូបត្ថម្ភម្នាក់មួយច្បាប់

ឧបករណ៍វាយតម្លៃខ្លួនឯងនេះចែកចេញជាបីកូលោន :

**កូលោនទីមួយ** គឺសកម្មភាពអាហារូបត្ថម្ភ

**កូលោនទីពីរ** គឺឱ្យអ្នកដាក់ពិន្ទុខ្លួនឯង។ ការដាក់ពិន្ទុត្រូវបានបែងចែកដូចនេះ :

- 0= មិនគ្រប់គ្រាន់
- ១= មធ្យម
- ២ = ល្អ
- ៣ = ល្អណាស់
- ៤ = ល្អឥតខ្ចោះ

នៅក្នុងផ្នែកនីមួយៗ សូមដាក់ពិន្ទុគ្រប់ចំណុចទាំងអស់ដែលបានរៀបរាប់នៅក្នុងផ្នែកនីមួយៗ ហើយបូកពិន្ទុសរុបនៃផ្នែកនីមួយៗ។ នៅចុងបញ្ចប់ បូកសរុបពិន្ទុសរុបនៃផ្នែកនីមួយៗ ដើម្បីបានពិន្ទុសរុបរួម។

**កូលោនទីបី** គឺឱ្យអ្នកកំណត់រកសកម្មភាពដែលត្រូវធ្វើបន្ត។

នៅពេលដែលបុគ្គលិកកម្មវិធីជាតិអាហារូបត្ថម្ភបានបំពេញទំរង់វាយតម្លៃខ្លួនឯងនេះចប់សព្វគ្រប់ហើយ សូមធ្វើការពិភាក្សាលទ្ធផលនៅក្នុងក្រុមធំ។ ធ្វើការសរសើរលើសកម្មភាពដែលមានដំណើរការល្អ និងធ្វើការពិភាក្សាលើសកម្មភាពដែលមិនសូវបានល្អ។ កំណត់រកវិធានការណ៍ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសកម្មភាពទាំងឡាយណាដែលមិនសូវល្អ។

មន្ត្រីគ្រប់គ្រងកម្មវិធីជាតិអាហារូបត្ថម្ភនឹងរក្សាកំណត់ហេតុនៃវិធានការណ៍ដែលបានផ្តល់អនុសាសន៍ ធ្វើការតាមដានលើវឌ្ឍនភាព និងធ្វើការពិភាក្សានៅពេលធ្វើការវាយតម្លៃលើកក្រោយ។ ការវាយតម្លៃដោយខ្លួនឯងនេះអាចធ្វើរាល់បីខែម្តង។

ពិន្ទុ : ០ = មិនគ្រប់គ្រាន់ ១ = មធ្យម ២ = ល្អ ៣ = ល្អណាស់ ៤ = ល្អឥតខ្ចោះ

ឧបករណ៍វាយតម្លៃខ្លួនឯងសំរាប់បុគ្គលិកកម្មវិធីជាតិអាហារូបត្ថម្ភ

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្ត្រសកម្មភាព |
|---|---|---|
| ១- ការពិនិត្យតាមដាន និងការអភិបាល | | |
| ពិនិត្យឡើងវិញនូវទិន្នន័យប្រព័ន្ធព័ត៌មានសុខាភិបាល (HIS) មុននឹងធ្វើផែនការចុះអភិបាល។ កំណត់រកស្រុកអាទិភាព ដោយយោងទៅតាមរបាយការណ៍សកម្មភាព និងទិន្នន័យប្រព័ន្ធព័ត៌មានសុខាភិបាល | | |
| ធ្វើផែនការអភិបាលប្រចាំត្រីមាស និងទទួលការឯកភាពដោយមន្ត្រីគ្រប់គ្រងកម្មវិធី | | |
| ការពិនិត្យតាមដាន និងការអភិបាលទាំងអស់នៃសកម្មភាព MPA ១០ នៅថ្នាក់ខេត្ត និងស្រុកបានធ្វើទៅតាមផែនការដែលបានគ្រោងទុកក្នុងអំឡុងពេលបីខែចុងក្រោយ | | |
| នៅថ្នាក់ខេត្ត ទំរង់វាយតម្លៃថ្នាក់ស្រុកកាលពីលើកមុនត្រូវបានពិនិត្យឡើងវិញ ហើយវិធានការណ៍តាមដានត្រូវបានពិភាក្សា | | |
| ឧបករណ៍វាយតម្លៃខ្លួនឯងត្រូវបានបំពេញដោយបុគ្គលិកថ្នាក់ខេត្ត និងស្រុក លទ្ធផលត្រូវបានលើកយកមកពិភាក្សា និងសកម្មភាពចំពោះវិធានការណ៍ដែលនឹងយកមកអនុវត្តន៍ត្រូវបានកំណត់ និងបានកត់ត្រាទុក | | |
| បញ្ហាដែលបានជួបប្រទះនៅក្នុងពេលពិនិត្យតាមដាន និងអភិបាល ត្រូវបានរាយការណ៍ទៅឱ្យមន្ត្រីគ្រប់គ្រងកម្មវិធីជាតិអាហារូបត្ថម្ភនៅថ្នាក់ជាតិ | | |
| ថតចំលងទំរង់វាយតម្លៃខ្លួនឯងថ្នាក់ខេត្ត និងសកម្មភាពតាមដាន បានប្រគល់ជូនឱ្យមន្ត្រីគ្រប់គ្រងកម្មវិធីជាតិអាហារូបត្ថម្ភនៅថ្នាក់ជាតិ | | |
| សរុប | | |

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្រ្តសកម្មភាព |
|---|---|---|
| ២- ការកត់ត្រា និងរបាយការណ៍ | | |
| ទទួលរបាយការណ៍ប្រព័ន្ធព័ត៌មានសុខាភិបាលប្រចាំខែពីខេត្តទាន់ពេលវេលា | | |
| រំលឹក និងទាក់ទងទៅកាន់ខេត្តដែលយឺតយ៉ាវក្នុងការផ្តល់ទិន្នន័យប្រព័ន្ធព័ត៌មានសុខាភិបាល | | |
| ពិនិត្យមើលនូវរបាយការណ៍ប្រព័ន្ធព័ត៌មានសុខាភិបាល ធ្វើការវិភាគ និងផ្តល់ព័ត៌មានត្រលប់យ៉ាងលឿនទៅឱ្យខេត្ត | | |
| ទិន្នន័យនៃប្រព័ន្ធព័ត៌មានសុខាភិបាលប្រចាំត្រីមាស និងឆ្នាំសំរាប់ខេត្តនីមួយៗ ត្រូវបានពិនិត្យមើលឡើងវិញ ហើយលទ្ធផលត្រូវបានសង្ខេបសំរាប់ខេត្តនីមួយៗដែលមានព័ត៌មានត្រលប់ | | |
| ឯកសារអេឡិកត្រូនិក ស្តីពីសេចក្តីសង្ខេបព័ត៌មានប្រចាំឆ្នាំបានផ្តល់ទៅឱ្យថ្នាក់ខេត្តមុនពេលធ្វើសិក្ខាសាលាពិនិត្យឡើងវិញ | | |
| សរុប | | |
| ៣- ការគ្រប់គ្រងស្តុកមីក្រូសារជាតិ | | |
| ការប៉ាន់ប្រមាណប្រចាំឆ្នាំសំរាប់គ្រាប់ថ្នាំជីវជាតិអា និងជាតិដែកត្រូវបានស្នើសុំទាន់ពេល | | |
| បានស្នើសុំ និងបានទទួលរបាយការណ៍ស្តុកប្រចាំត្រីមាសពីឃ្លាំងឱសថកណ្តាល (CMS) | | |
| តាមដានទាន់ពេលនូវរបាយការណ៍ដាច់ស្តុករបស់ខេត្ត | | |
| អ្នកអភិបាលកម្មវិធីជាតិអាហារូបត្ថម្ភបានធ្វើបញ្ជីសារពើភ័ណ្ឌស្តុកប្រចាំត្រីមាស នៃគ្រាប់ថ្នាំជីវជាតិអា គ្រាប់ថ្នាំជាតិដែក និងគ្រាប់ថ្នាំទំលាក់ព្រូននៅក្នុងអំឡុងការចុះអភិបាល (តុល្យភាពស្តុក គុណភាព កាលបរិច្ឆេទការប្រើប្រាស់ ថ្ងៃនៃការដាច់ស្តុក) | | |
| សរុប | | |

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្ត្រសកម្មភាព |
|---|---|---|
| ៤- ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា ពីរដងក្នុងមួយឆ្នាំ | | |
| ខេត្ត និងស្រុកដែលមានការគ្រប់ដណ្តប់ទាបត្រូវបានកំណត់រក សំរាប់គាំទ្រ នៅក្នុងអំឡុងពេលជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា ហើយផែនការអភិបាលត្រូវបានពិភាក្សាជាមួយមន្ត្រីគ្រប់គ្រងកម្មវិធី | | |
| ចូលរួមនៅក្នុងការប្រជុំធ្វើផែនការជាមួយខេត្តគោលដៅ | | |
| ចែកចាយសំភារៈអប់រំទៅឱ្យគ្រប់ខេត្តទាំងអស់ប្រសិនបើមាន | | |
| គុណភាព បរិមាណ កាលបរិច្ឆេទការប្រើប្រាស់ និងការប៉ាន់ប្រមាណនូវតំរូវការគ្រាប់ថ្នាំជីវជាតិអា ត្រូវបានពិនិត្យមើលនៅក្នុងខេត្តនីមួយៗមុនពេលជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា ត្រូវបានត្រួតពិនិត្យដោយបុគ្គលិកកម្មវិធីអាហារូបត្ថម្ភនៅក្នុងខេត្ត ស្រុកដែលបានផ្តល់អាទិភាព | | |
| បានពិនិត្យឡើងវិញនូវទិន្នន័យប្រព័ន្ធព័ត៌មានសុខាភិបាលនៃគ្រាប់ថ្នាំជីវជាតិអា និងផ្តល់ព័ត៌មានត្រលប់ទៅឱ្យខេត្តទាំងឡាយវិញយ៉ាងឆាប់អំពីជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| បុគ្គលិកកម្មវិធីអាហារូបត្ថម្ភបានធ្វើការតាមដានភ្លាមៗនៅក្នុងស្រុក/ខេត្តដែលមានការគ្រប់ដណ្តប់ទាប | | |
| លទ្ធផលនៃជុំចែកចាយគ្រាប់ថ្នាំជីវជាតិអាថ្នាក់ជាតិត្រូវបានបង្ហាញ និងពិភាក្សាជាមួយបុគ្គលិកខេត្ត/ស្រុកនៅក្នុងសិក្ខាសាលាពិនិត្យឡើងវិញប្រចាំឆ្នាំ | | |
| សរុប | | |

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្ត្រសកម្មភាព |
|---|---|---|
| ៥- ព្រឹត្តិការណ៍ពិសេសៗ អំពីអាហារូបត្ថម្ភ | | |
| ការប្រជុំជាមួយខេត្តអាទិភាពដើម្បីធ្វើផែនការសកម្មភាពសំរាប់សប្តាហ៍ពិភពលោកបំបៅកូនដោយទឹកដោះម្តាយ | | |
| បានចែកចាយសំភារៈអប់រំគ្រប់គ្រាន់ទៅឱ្យខេត្តទាំងអស់ | | |
| ព្រឹត្តិការណ៍ផ្សេងៗទៀត | | |
| សរុប | | |
| ពិន្ទុសរុប | | |
| ការដាក់ពិន្ទុ : 0= មិនគ្រប់គ្រាន់, ១=មធ្យម , ២ = ល្អ , ៣ = ល្អណាស់ , ៤ = ល្អឥតខ្ចោះ | | |

## ការតាមដានផែនការសកម្មភាព

| កាលបរិច្ឆេទ | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ហត្ថលេខាអ្នកអភិបាល |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

២

# ឧបករណ៍វាយតម្លៃខ្លួនឯងសំរាប់ អ្នកអភិបាលថ្នាក់ខេត្ត

ឧបករណ៍វាយតម្លៃខ្លួនឯងនេះ នឹងត្រូវបានយកមកប្រើប្រាស់នៅពេលចុះអភិបាលដោយកម្មវិធីអាហារូបត្ថម្ភ

### របៀបប្រើប្រាស់ឧបករណ៍នេះ

### ១- អ្នកអភិបាលកម្មវិធីជាតិអាហារូបត្ថម្ភ នឹងបង្ហាញពីឧបករណ៍វាយតម្លៃទៅអ្នកអភិបាលថ្នាក់ខេត្ត

ឧបរណ៍វាយតម្លៃនេះផ្តល់ឱកាសដល់អ្នកអភិបាលថ្នាក់ខេត្ត ក្នុងការកំណត់រកសកម្មភាពអាហារូបត្ថម្ភ ដែលមានដំណើរការល្អនៅក្នុងខេត្តរបស់គាត់ និងសកម្មភាពដែលចាំបាច់ត្រូវពង្រឹងបន្ថែម។ ឧបករណ៍នេះក៏ផ្តល់ឱកាសឱ្យក្រុមកម្មវិធីជាតិអាហារូបត្ថម្ភ និងបុគ្គលិកថ្នាក់ខេត្តធ្វើការជាមួយគ្នា ក្នុងការកំណត់រកនូវវិធីដើម្បីពង្រឹងសកម្មភាពទាំងឡាយ និងឯកភាពលើវិធានការណ៍មួយចំនួន ដែលនឹងយកមកអនុវត្ត។

អ្នកអភិបាលថ្នាក់ខេត្តធ្វើការជាក្រុមដើម្បីបំពេញទំរង់នេះ ហើយបន្ទាប់មកប្រើទំរង់នេះដើម្បីធ្វើការពិភាក្សាជាមួយអ្នកអភិបាលកម្មវិធីជាតិអាហារូបត្ថម្ភ ។

### ២- អ្នកអភិបាលកម្មវិធីជាតិអាហារូបត្ថម្ភ ធ្វើការបង្ហាញ និងពន្យល់ពីទំរង់វាយតម្លៃខ្លួនឯងនេះ។ ផ្តល់ទំរង់នេះឱ្យអ្នកចូលរួមម្នាក់មួយច្បាប់

ឧបករណ៍វាយតម្លៃខ្លួនឯងនេះចែកចេញជាបីកូលោន :

កូលោនទីមួយ  គឺសកម្មភាពអាហារូបត្ថម្ភនៅថ្នាក់ខេត្ត

កូលោនទីពីរ គឺឱ្យអ្នកដាក់ពិន្ទុខ្លួនឯង។ ការដាក់ពិន្ទុត្រូវបានបែងចែកដូចនេះ :

- 0= មិនគ្រប់គ្រាន់
- ១= មធ្យម
- ២ = ល្អ
- ៣ = ល្អណាស់
- ៤ = ល្អឥតខ្ចោះ

នៅក្នុងផ្នែកនីមួយៗ សូមដាក់ពិន្ទុគ្រប់ចំណុចទាំងអស់ដែលបានរៀបរាប់នៅក្នុងផ្នែកនីមួយៗ ដើម្បីបានពិន្ទុសរុបនៃផ្នែកនីមួយៗ។ នៅចុងបញ្ចប់ បូកសរុបពិន្ទុសរុបនៃផ្នែកនីមួយៗ ដើម្បីបានពិន្ទុសរុបរួម។

កូលោនទីបី គឺឱ្យអ្នកកំណត់រកសកម្មភាពដែលត្រូវតាមដានបន្ត។ កំណត់រកផ្នែកដែលមានពិន្ទុទាបជាងគេ។

នៅពេលដែលទំរង់វាយតម្លៃខ្លួនឯងនេះត្រូវបានបំពេញចប់សព្វគ្រប់ហើយ សូមធ្វើការពិភាក្សាលទ្ធផលជាមួយអ្នកអភិបាលកម្មវិធីអាហារូបត្ថម្ភ។ ទទួលស្គាល់នូវសកម្មភាពដែលមានដំណើរការល្អ និងសសើរបុគ្គលិក ចំពោះការខិតខំប្រឹងប្រែងរបស់ពួកគាត់។ ធ្វើការពិភាក្សាលើសកម្មភាពដែលមិនសូវបានល្អ។ កំណត់រកវិធានការណ៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវសកម្មភាពទាំងឡាយណាដែលមិនសូវល្អ។

អ្នកអភិបាលថ្នាក់ខេត្ត និងអ្នកអភិបាលកម្មវិធីជាតិអាហារូបត្ថម្ភ នឹងរក្សាទុកកំណត់ហេតុ នៃវិធានការណ៍ដែលបានផ្តល់អនុសាសន៍ និងធ្វើការតាមដានលើវឌ្ឍនភាព និងធ្វើការពិភាក្សានៅពេលធ្វើការវាយតម្លៃលើកក្រោយ។

ពិន្ទុ ៖ ០ = មិនគ្រប់គ្រាន់   ១ = មធ្យម   ២ = ល្អ   ៣ = ល្អណាស់   ៤ = ល្អឥតខ្ចោះ

## ឧបករណ៍វាយតម្លៃខ្លួនឯងសំរាប់អ្នកអភិបាលថ្នាក់ខេត្ត

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្ត្រសកម្មភាព |
|---|---|---|
| ១- សកម្មភាពអាហារូបត្ថម្ភដាក់បញ្ចូលទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ | | |
| ផែនការប្រតិបត្តិប្រចាំឆ្នាំរួមមានថវិកាសំរាប់សកម្មភាពអាហារូបត្ថម្ភ ដូចជាសប្តាហ៍ពិភពលោកបំបៅកូនដោយទឹកដោះម្តាយ | | |
| ថវិកាសំរាប់សកម្មភាពអាហារូបត្ថម្ភត្រូវបានស្នើសុំ និងផ្តល់ទៅឱ្យស្រុកទាន់ពេល | | |
| តាមដានបញ្ហាថវិកាយ៉ាងឆាប់រហ័ស | | |
| ការពិនិត្យឡើងវិញបំណាច់ឆ្នាំត្រូវបានធ្វើឡើងជាមួយស្រុកប្រតិបត្តិ | | |
| កំណត់សូចនករ និងគោលដៅប្រចាំឆ្នាំសំរាប់សកម្មភាពអាហារូបត្ថម្ភ | | |
| សរុប | | |
| ២- ការពិនិត្យតាមដាន និងការអភិបាល | | |
| ពិនិត្យឡើងវិញនូវទិន្នន័យប្រព័ន្ធព័ត៌មានសុខាភិបាល (HIS) និងកំណត់រកស្រុកអាទិភាពសំរាប់ការចុះពិនិត្យតាមដាន | | |
| បានចុះពិនិត្យតាមដាន និងអភិបាលនៃសកម្មភាព MPA ១០ នៅថ្នាក់ស្រុកប្រតិបត្តិ ទៅតាមផែនការដែលបានគ្រោងទុកក្នុងអំឡុងពេលបីខែចុងក្រោយ | | |
| ឧបករណ៍វាយតម្លៃខ្លួនឯងត្រូវបានផ្តល់ឱ្យអ្នកអភិបាលស្រុកប្រតិបត្តិ។ លទ្ធផលត្រូវបានលើកយកមកពិភាក្សា និងសកម្មភាពចំពោះវិធានការណ៍ដែលនឹងយកមកអនុវត្តត្រូវបានកំណត់ និងត្រូវបានកត់ត្រាទុក | | |
| បញ្ហាដែលបានជួបប្រទះនៅក្នុងអំឡុងពេលចុះពិនិត្យតាមដាន និងអភិបាល ត្រូវបានរាយការណ៍ទៅឱ្យប្រធានមន្ទីរសុខាភិបាលខេត្ត | | |

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្ត្រសកម្មភាព |
|---|---|---|
| របាយការណ៍នៃការអភិបាលត្រូវបានផ្ញើទៅឱ្យប្រធានមន្ទីរសុខាភិបាលខេត្ត និងទុកជាឯកសារ | | |
| សរុប | | |
| ៣- ការកត់ត្រា និងរបាយការណ៍ | | |
| ទទួលរបាយការណ៍ប្រព័ន្ធព័ត៌មានសុខាភិបាលប្រចាំខែពីស្រុកប្រតិបត្តិទាន់ពេល | | |
| ពិនិត្យមើលឡើងវិញ វិភាគនូវរបាយការណ៍ប្រព័ន្ធព័ត៌មានសុខាភិបាលដែលទទួលពីថ្នាក់ស្រុក និងផ្តល់ព័ត៌មានត្រលប់ទៅឱ្យស្រុកប្រតិបត្តិវិញនៅពេលប្រជុំប្រចាំខែជាមួយស្រុកប្រតិបត្តិ | | |
| ចងក្រង និងផ្ញើរបាយការណ៍ប្រព័ន្ធព័ត៌មានសុខាភិបាលប្រចាំខែទៅឱ្យថ្នាក់ជាតិទាន់ពេល | | |
| សរុប | | |
| ៤- ការគ្រប់គ្រងស្តុកមីក្រូសារជាតិ | | |
| បានទទួលសំណើប្រចាំត្រីមាសទាន់ពេលវេលាពីស្រុកប្រតិបត្តិ ស្តីពីគ្រាប់ថ្នាំ ជីវជាតិអា គ្រាប់ថ្នាំជាតិដែក និងរបស់ប្រើប្រាស់អាហារូបត្ថម្ភផ្សេងៗទៀត | | |
| ធ្វើសំណើសុំការផ្គត់ផ្គង់មីក្រូសារជាតិផ្ញើរទៅឃ្លាំងឱសថកណ្តាលទាន់ពេល | | |
| ធ្វើបញ្ជីសារពើភ័ណ្ឌប្រចាំត្រីមាសនៃគ្រាប់ថ្នាំជីវជាតិអា គ្រាប់ថ្នាំជាតិដែក និងគ្រាប់ថ្នាំទំលាក់ព្រូននៅឃ្លាំងឱសថស្រុកប្រតិបត្តិ( បរិមាណ គុណភាព កាលបរិច្ឆេទការប្រើប្រាស់) | | |
| សរុប | | |
| ៥- ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា ពីរដងក្នុងមួយឆ្នាំ | | |
| ធ្វើការប្រជុំជាមួយស្រុកប្រតិបត្តិដើម្បីពិភាក្សា និងធ្វើផែនការពីជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| ថវិកាសំរាប់ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា ត្រូវបានចែកចាយទៅឱ្យស្រុកទាន់ពេល | | |
| ចែកចាយសំភារៈអប់រំទៅឱ្យគ្រប់ស្រុកទាំងអស់ ប្រសិនបើមាន | | |

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្ត្រសកម្មភាព |
|---|---|---|
| បរិមាណស្តុកនៃគ្រាប់ថ្នាំជីវជាតិអា ត្រូវបានពិនិត្យមើលដោយស្រុកប្រតិបត្តិ និងពិនិត្យមើលផងដែរនូវគុណភាព និងកាលបរិច្ឆេទការប្រើប្រាស់ | | |
| ស្រុកប្រតិបត្តិដែលមានការគ្រប់ដណ្តប់ទាបត្រូវបានពិនិត្យតាមដាន ដោយអ្នកអភិបាលថ្នាក់ខេត្ត នៅពេលជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| បានពិនិត្យឡើងវិញនូវទិន្នន័យប្រព័ន្ធព័ត៌មានសុខាភិបាលនៃគ្រាប់ថ្នាំជីវជាតិអា និងផ្តល់ព័ត៌មានត្រលប់ទៅឱ្យស្រុកអំពីការងាររបស់ពួកគេនៅក្នុងអំឡុងពេលការប្រជុំប្រចាំខែ | | |
| សរុប | | |
| ៦- ព្រឹត្តិការណ៍ពិសេសៗ | | |
| ការប្រជុំរៀបចំធ្វើផែនការសកម្មភាព ឧ. សំរាប់សប្តាហ៍ពិភពលោក បំបៅកូនដោយទឹកដោះម្តាយ | | |
| បានចែកចាយសំភារៈអប់រំគ្រប់គ្រាន់ទៅឱ្យស្រុកប្រតិបត្តិទាំងអស់ | | |
| ព្រឹត្តការណ៍ផ្សេងៗទៀត | | |
| សរុប | | |
| ពិន្ទុសរុប | | |
| ការដាក់ពិន្ទុ ៖ 0= មិនគ្រប់គ្រាន់, ១=មធ្យម , ២ = ល្អ , ៣ = ល្អណាស់ , ៤ = ល្អឥតខ្ចោះ | | |

## ការតាមដានផែនការសកម្មភាព

| កាលបរិច្ឆេទ | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ហត្ថលេខាអ្នកអភិបាល |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

# ឧបករណ៍វាយតម្លៃខ្លួនឯងសំរាប់ អ្នកអភិបាលស្រុកប្រតិបត្តិ

ឧបករណ៍វាយតម្លៃខ្លួនឯងនេះនឹងត្រូវបានយកមកប្រើប្រាស់ក្នុងពេលចុះអភិបាលរបស់ថ្នាក់ខេត្ត

## របៀបប្រើប្រាស់ឧបករណ៍នេះ

### ១- អ្នកអភិបាលថ្នាក់ខេត្តនឹងបង្ហាញឧបករណ៍នេះទៅអ្នកអភិបាលស្រុកប្រតិបត្តិ

ឧបករណ៍វាយតម្លៃនេះផ្តល់ឱកាសសំរាប់អ្នកអភិបាលថ្នាក់ស្រុក កំណត់រកនូវសកម្មភាពអាហារូបត្ថម្ភណាដែលមានដំណើរការល្អនៅក្នុងស្រុកប្រតិបត្តិនិងសកម្មភាពចាំបាច់ត្រូវពង្រឹងបន្ថែម។ ឧបករណ៍នេះក៏ផ្តល់ឱកាសឱ្យអ្នកអភិបាលខេត្ត និងស្រុកធ្វើការជាមួយគ្នាក្នុងការកំណត់រកមធ្យោបាយដើម្បីពង្រឹងសកម្មភាពទាំងនោះ និងឯកភាពគ្នាលើវិធានការណ៍ដែលនឹងយកមកអនុវត្តន៏។

អ្នកអភិបាលថ្នាក់ស្រុកប្រតិបត្តិ និងធ្វើការជាក្រុមដើម្បីបំពេញទំរង់នេះ ហើយបន្ទាប់មកប្រើទំរង់នេះដើម្បីធ្វើការពិភាក្សាជាមួយអ្នកអភិបាលថ្នាក់ខេត្ត។

### ២- អ្នកអភិបាលថ្នាក់ខេត្តធ្វើការបង្ហាញ និងពន្យល់ពីទំរង់វាយតម្លៃខ្លួនឯង។ ផ្តល់ទំរង់នេះទៅឱ្យគ្រប់អ្នកចូលរួមទាំងអស់។

ឧបករណ៍វាយតម្លៃខ្លួនឯងនេះចែកចេញជាបីកូលោន :

**កូលោនទីមួយ** គឺសកម្មភាពអាហារូបត្ថម្ភនៅថ្នាក់ស្រុក

**កូលោនទីពីរ** គឺឱ្យអ្នកដាក់ពិន្ទុខ្លួនឯង។ ការដាក់ពិន្ទុត្រូវបានបែងចែកដូចនេះ :

- 0= មិនគ្រប់គ្រាន់
- ១= មធ្យម
- ២ = ល្អ
- ៣ = ល្អណាស់
- ៤ = ល្អឥតខ្ចោះ

នៅក្នុងផ្នែកនីមួយៗ សូមដាក់ពិន្ទុគ្រប់ចំណុចទាំងអស់ដែលបានរៀបរាប់នៅក្នុងផ្នែកនីមួយៗ ដើម្បីបានពិន្ទុសរុបនៃផ្នែកនីមួយៗ។ នៅចុងបញ្ចប់បូកសរុបពិន្ទុសរុបនៃផ្នែកនីមួយៗ ដើម្បីបានពិន្ទុសរុបរួម។

**កូលោនទីបី** គឺឱ្យអ្នកកំណត់រកសកម្មភាពដែលត្រូវតាមដានបន្ត។ កំណត់រកផ្នែកដែលមានពិន្ទុទាបជាងគេ។

នៅពេលដែលទំរង់វាយតម្លៃខ្លួនឯងនេះបានបំពេញចប់សព្វគ្រប់ហើយ សូមធ្វើការពិភាក្សាលទ្ធផលជាមួយអ្នកអភិបាលថ្នាក់ខេត្ត។ ធ្វើការសរសើរលើសកម្មភាពដែលមានដំណើរការល្អ និងធ្វើការពិភាក្សាលើសកម្មភាពដែលមិនសូវបានល្អ។ កំណត់រកវិធានការណ៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវសកម្មភាពទាំងឡាយណាដែលមិនសូវល្អ។

អ្នកអភិបាលថ្នាក់ស្រុក និងខេត្តនឹងរក្សាកំណត់ហេតុនៃវិធានការណ៍ដែលបានផ្តល់អនុសាសន៏ និងធ្វើការតាមដានលើវឌ្ឍនភាព និងធ្វើការពិភាក្សានៅពេលអភិបាលលើកក្រោយ។

ពិន្ទុ : ០ = មិនគ្រប់គ្រាន់ ១ = មធ្យម ២ = ល្អ ៣ = ល្អណាស់ ៤ = ល្អឥតខ្ចោះ

ឧបករណ៍វាយតម្លៃខ្លួនឯងសំរាប់អ្នកអភិបាលថ្នាក់ស្រុក

| សកម្មភាពគន្លឹះ | ពិន្ទុ | អនុសាស្ត្រសកម្មភាព |
|---|---|---|
| ១- អាហារូបត្ថម្ភត្រូវបានដាក់បញ្ចូលទៅក្នុងផែនការប្រិតបត្តិប្រចាំឆ្នាំ | | |
| ផែនការប្រតិបត្តិប្រចាំឆ្នាំរួមមានថវិកាសំរាប់សកម្មភាពអាហារូបត្ថម្ភ | | |
| ដូចជាសប្តាហ៍បំបៅកូនដោយទឹកដោះម្តាយជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| ថវិកាសំរាប់សកម្មភាពអាហារូបត្ថម្ភ បានស្នើសុំ និងផ្តល់ទៅឱ្យមណ្ឌលសុខភាពទាន់ពេលសំរាប់អនុវត្តសកម្មភាពដែលបានគ្រោងទុក | | |
| ធ្វើការពិនិត្យឡើងវិញជាមួយមណ្ឌលសុខភាពនៅបំណាច់ឆ្នាំ | | |
| អាំងឌីកាទ័រ និងគោលដៅប្រចាំឆ្នាំទាក់ទងទៅនឹងសកម្មភាពអាហារូបត្ថម្ភដែលបានកំណត់ | | |
| សរុប | | |
| ២- ការអភិបាល និងការពិនិត្យតាមដាន | | |
| មណ្ឌលសុខភាពដែលបានកំណត់រកបញ្ហា និងបានបង្កើតផែនការអភិបាល និងការពិនិត្យតាមដាន | | |
| ការអភិបាល និងពិនិត្យតាមដាននៃសកម្មភាព MPA ១០ នៅមណ្ឌលសុខភាពបានអនុវត្តតាមផែនការនៅក្នុងអំឡុងពេល បីខែចុងក្រោយ | | |
| ទិន្នន័យប្រព័ន្ធព័ត៌មានសុខាភិបាលបានធ្វើការពិនិត្យឡើងវិញមុនពេលមានការចុះអភិបាល និងកំណត់រកបញ្ហា | | |
| បានផ្តល់ឧបករណ៍វាយតម្លៃខ្លួនឯងឱ្យមណ្ឌលសុខភាព។ ពិភាក្សាបញ្ហា និងកំណត់រកវិធានការណ៍សំរាប់សកម្មភាពព្រមទាំងធ្វើការកត់ត្រារាល់សកម្មភាពទាំងនោះ | | |

| សកម្មភាពគន្លឹះ | ពិន្ទុ | អនុសាស្ត្រសកម្មភាព |
|---|---|---|
| រាល់បញ្ហាដែលបានជួបប្រទះនៅពេលចុះអភិបាល និងពិនិត្យតាមដានបានរាយការណ៍ទៅឱ្យប្រធានស្រុកប្រតិបត្តិ | | |
| របាយការណ៍អភិបាលត្រូវបានផ្ញើរទៅឱ្យប្រធានស្រុកប្រតិបត្តិ និងទុកជាឯកសារ | | |
| សរុប | | |
| ៣- ការកត់ត្រា និងរបាយការណ៍ | | |
| របាយការណ៍ប្រចាំខែ HIS បានទទួលពីមណ្ឌលសុខភាពទាន់ពេលវេលា | | |
| ពិនិត្យឡើងវិញនូវរបាយការណ៍ HIS ពីមណ្ឌលសុខភាព និងផ្តល់ព័ត៌មានត្រលប់ទៅឱ្យមណ្ឌលសុខភាពនៅពេលប្រជុំប្រចាំខែ នៅស្រុកប្រតិបត្តិ | | |
| ចងក្រងបញ្ចូលគ្នានូវរបាយការណ៍ប្រចាំខែ HIS និងផ្ញើរទៅមន្ទីរសុខាភិបាលខេត្តទាន់ពេល | | |
| សរុប | | |
| ៤- ការគ្រប់គ្រងស្តុក | | |
| សំណើរគ្រាប់ថ្នាំជីវជាតិអា គ្រាប់ថ្នាំជាតិដែក និងគ្រាប់ថ្នាំទំលាក់ព្រូន ប្រចាំខែ និងត្រីមាស បានទទួលពីមណ្ឌលសុខភាពទាន់ពេល | | |
| សំណើរសុំផ្គត់ផ្គង់មីក្រូសារជាតិបានផ្ញើរទៅថ្នាក់ខេត្តទាន់ពេល | | |
| ធ្វើបញ្ជីសារពើភ័ណ្ឌអំពីគ្រាប់ ថ្នាំជីវជាតិអា ជាតិដែក និងថ្នាំទំលាក់ព្រូន ត្រូវបានធ្វើប្រចាំត្រីមាស (បរិមាណ គុណភាព កាលបរិច្ឆេទ) | | |
| សរុប | | |

| សកម្មភាពគន្លឹះ | ពិន្ទុ | អនុសាស្រ្តសកម្មភាព |
| --- | --- | --- |
| ៥- ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា ពីរដងក្នុងមួយឆ្នាំ | | |
| ប្រជុំជាមួយបុគ្គលិកមណ្ឌលសុខភាព ដើម្បីពិភាក្សា និងធ្វើផែនការពីជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| ផ្តល់ថវិកាសំរាប់ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអាទាន់ពេលទៅឱ្យមណ្ឌលសុខភាព | | |
| ចែកចាយសំភារៈអប់រំទៅឱ្យមណ្ឌលសុខភាពបើមាន | | |
| គុណភាព បរិមាណ និងកាលបរិច្ឆេទហួសកំណត់នៃស្តុកជីវជាតិអាត្រូវបានពិនិត្យ | | |
| ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអាត្រូវបានពិនិត្យតាមដានដោយអ្នកអភិបាលថ្នាក់ស្រុក | | |
| បានពិនិត្យមើលឡើងវិញនូវទិន្នន័យប្រព័ន្ធព័ត៌មានសុខាភិបាលនៃគ្រាប់ថ្នាំជីវជាតិអា និងផ្តល់ព័ត៌មានមានត្រលប់ទៅឱ្យបុគ្គលិកមណ្ឌលសុខភាពវិញយ៉ាងឆាប់អំពីជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា នៅពេលប្រជុំមណ្ឌលសុខភាព/ស្រុកប្រតិបត្តិ | | |
| បានធ្វើសកម្មភាពបង្គ្រប់នៅតំបន់ដែលមានការគ្របដណ្តប់ទាប | | |
| សរុប | | |
| ៦- ព្រឹត្តិការណ៍ពិសេសៗ | | |
| ព្រឹត្តិការណ៍ផ្សេងៗទៀត | | |
| ការប្រជុំជាមួយមណ្ឌលសុខភាពដើម្បីធ្វើផែនការសកម្មភាព ឧ.សំរាប់សប្តាហ៍ពិភពលោកបំបៅកូនដោយទឹកដោះម្តាយ | | |
| បានចែកចាយសំភារៈអប់រំដែលមានទៅឱ្យគ្រប់មណ្ឌលសុខភាព | | |
| សរុប | | |
| ពិន្ទុសរុប | | |
| ការដាក់ពិន្ទុ : 0= មិនគ្រប់គ្រាន់, ១=មធ្យម , ២ = ល្អ , ៣ = ល្អណាស់ , ៤ = ល្អឥតខ្ចោះ | | |

## ការតាមដានផែនការសកម្មភាព

| កាលបរិច្ឆេទ | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ហត្ថលេខាអ្នកអភិបាល |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

# ឧបករណ៍វាយតម្លៃខ្លួនឯងសំរាប់ បុគ្គលិកមណ្ឌលសុខភាព

ឧបករណ៍វាយតម្លៃខ្លួនឯងនេះនឹងត្រូវបានយកមកប្រើប្រាស់ក្នុងពេលចុះអភិបាលដោយអ្នកអភិបាលថ្នាក់ស្រុកប្រតិបត្តិ

## របៀបប្រើប្រាស់ឧបករណ៍នេះ

### ១- អ្នកអភិបាល ថ្នាក់ស្រុកនឹងបង្ហាញឧបករណ៍នេះទៅបុគ្គលិកមណ្ឌលសុខភាព

ឧបរណ៍វាយតម្លៃនេះផ្តល់ឱកាសដល់បុគ្គលិកមណ្ឌលសុខភាពកំណត់រកនូវសកម្មភាពអាហារូបត្ថម្ភដែលមានដំណើរការល្អនៅក្នុងតំបន់គ្របដណ្តប់នៃមណ្ឌលសុខភាពរបស់គាត់ និងសកម្មភាពដែលចាំបាច់ត្រូវពង្រឹងបន្ថែម។ ឧបករណ៍នេះក៏ផ្តល់ឱកាសដល់បុគ្គលិកមណ្ឌលសុខភាព និងអ្នកអភិបាលថ្នាក់ស្រុក ធ្វើការជាមួយគ្នាក្នុងការកំណត់រកមធ្យោបាយដើម្បីពង្រឹងសកម្មភាពទាំងឡាយ និងឯកភាពគ្នាលើវិធានការណ៍ដែលនឹងយកមកអនុវត្ត។

បុគ្គលិកមណ្ឌលសុខភាពនឹងធ្វើការជាក្រុមដើម្បីបំពេញទំរង់នេះ ហើយបន្ទាប់មកប្រើទំរង់នេះដើម្បីធ្វើការពិភាក្សាជាមួយអ្នកអភិបាលថ្នាក់ស្រុកប្រតិបត្តិ។

### ២- អ្នកអភិបាលថ្នាក់ស្រុក ពន្យល់ពីទំរង់វាយតម្លៃខ្លួនឯងនេះ។ ផ្តល់ទំរង់នេះទៅឱ្យគ្រប់អ្នកចូលរួមទាំងអស់។

ឧបករណ៍វាយតម្លៃខ្លួនឯងនេះចែកចេញជាបីកូលោន :

**កូលោនទីមួយ** គឺសកម្មភាពអាហារូបត្ថម្ភនៅថ្នាក់មណ្ឌលសុខភាព

**កូលោនទីពីរ** គឺឱ្យដាក់ពិន្ទុខ្លួនឯង។ ការដាក់ពិន្ទុត្រូវបានបែងចែកដូចនេះ :

- 0= មិនគ្រប់គ្រាន់
- ១= មធ្យម
- ២ = ល្អ
- ៣ = ល្អណាស់
- ៤ = ល្អឥតខ្ចោះ

នៅក្នុងផ្នែកនីមួយៗ សូមដាក់ពិន្ទុគ្រប់ចំណុចទាំងអស់ដែលបានរៀបរាប់នៅក្នុងផ្នែកនីមួយៗ ហើយបូកពិន្ទុទាំងនោះចូលគ្នាដើម្បីបានពិន្ទុសរុបសំរាប់ផ្នែកនីមួយៗ។ នៅចុងបញ្ចប់ បូកសរុបពិន្ទុសរុបនៃផ្នែកនីមួយៗ ដើម្បីបានពិន្ទុសរុបរួម។

**កូលោនទីបី** គឺឱ្យកំណត់រកសកម្មភាពត្រូវធ្វើបន្ត។ កំណត់រកផ្នែកដែលមានពិន្ទុទាបជាងគេ។

នៅពេលដែលទំរង់វាយតម្លៃខ្លួនឯងនេះបានបំពេញចប់សព្វគ្រប់ហើយ ធ្វើការពិភាក្សាលទ្ធផលជាមួយអ្នកអភិបាលថ្នាក់ស្រុក។ ធ្វើការសរសើរលើសកម្មភាពដែលមានដំណើរការល្អដល់បុគ្គលិកមណ្ឌលសុខភាពចំពោះសមិទ្ធិផលរបស់ពួកគាត់។ ធ្វើការពិភាក្សាលើសកម្មភាពដែលមិនសូវបានល្អ។ កំណត់រកវិធានការណ៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវសកម្មភាពទាំងឡាយណាដែលមិនសូវល្អ។

បុគ្គលិកមណ្ឌលសុខភាព និងអ្នកអភិបាលថ្នាក់ស្រុកនឹងរក្សាកំណត់ហេតុនៃវិធានការណ៍ទាំងឡាយដែលបានផ្តល់ជាអនុសាសន៍ និងធ្វើការតាមដានលើវឌ្ឍនភាព ហើយនឹងធ្វើការពិភាក្សានៅអំឡុងពេលនៃការអភិបាលលើកក្រោយ។

ពិន្ទុ ៖ ០ = មិនគ្រប់គ្រាន់ ១ = មធ្យម ២ = ល្អ ៣ = ល្អណាស់ ៤ = ល្អឥតខ្ចោះ

ឧបករណ៍វាយតម្លៃខ្លួនឯងសំរាប់បុគ្គលិកមណ្ឌលសុខភាព

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្ត្រសកម្មភាព |
|---|---|---|
| ១- ការពិនិត្យផ្ទៃទាំផ្ទៃពោះមុនពេលសំរាល | | |
| គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់នៅក្នុងតំបន់គ្របដណ្តប់ទទួលគ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលីក៦០គ្រាប់នៅពេលជួបពិនិត្យលើកទី១ និងទទួល ៣០គ្រាប់នៅពេលជួបពិនិត្យលើកទី២ | | |
| គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់បានទទួលការផ្តល់ប្រឹក្សាពីរបៀបលេបគ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលីក និងអំពីផលរំខាននៃថ្នាំហើយ និងអំពីការគ្រប់គ្រងផលរំខាននៃថ្នាំ | | |
| គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់បានពិនិត្យស្រាវជ្រាវរកមើលភាពស្លេកស្លាំងបាតដៃរាល់ការមកជួបពិនិត្យ | | |
| ស្ត្រីមានផ្ទៃពោះដែលមានបាតដៃស្លេកស្លាំងបានទទួលការព្យាបាលតាមគោលការណ៍ថ្នាក់ជាតិសំរាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលីក | | |
| គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់ បានទទួលគ្រាប់ថ្នាំទំលាក់ព្រូនពោះវៀនបន្ទាប់ពីត្រីមាសទីមួយ នៃការមានផ្ទៃពោះ | | |
| គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់ បានទទួលការផ្តល់ប្រឹក្សាពីការបរិភោគអាហារបន្ថែមមួយពេលក្នុងមួយថ្ងៃនៅក្នុងអំឡុងពេលនៃការមានផ្ទៃពោះ និងបរិភោគអាហារប្រភេទផ្សេងៗគ្នាអោយច្រើន | | |
| គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់បានទទួលការផ្តល់ប្រឹក្សាអំពីសារៈសំខាន់នៃការប្រើអំបិលអ៊ីយ៉ូដនៅក្នុងអាហារគ្រួសារ | | |
| គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់បានទទួលការផ្តល់ប្រឹក្សាអំពីការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រយៈពេល៦ខែ | | |

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្រ្តសកម្មភាព |
|---|---|---|
| គ្រប់ស្រ្តីមានផ្ទៃពោះទាំងអស់បានទទួលព័ត៌មានអំពីការបំបៅកូនដោយទឹកដោះម្តាយភ្លាមក្រោយសម្រាល និងការដាក់ឱ្យស្បែកប៉ះស្បែក | | |
| សរុប | | |
| ២- ការថែទាំក្រោយសម្រាល | | |
| គ្រប់ម្តាយទាំងអស់ត្រូវបានគាំទ្រឱ្យដាក់ស្បែកប៉ះស្បែក | | |
| គ្រប់ម្តាយទាំងអស់បំបៅកូនដោយទឹកដោះម្តាយនៅក្នុងរយៈពេល១ម៉ោងដំបូងបន្ទាប់ពីសម្រាល | | |
| គ្រប់ម្តាយទាំងអស់បានទទួលការផ្តល់ប្រឹក្សាអំពីការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់នៅក្នុងរយៈពេល៦ខែដំបូង | | |
| គ្រប់ម្តាយទាំងអស់បានទទួលដំបូន្មានពីការបំបៅកូនឱ្យបានញឹកញាប់ទៅតាមតំរូវការទាំងថ្ងៃ និងយប់ (យ៉ាងហោចណាស់ ៨ដង) | | |
| គ្រប់ម្តាយទាំងអស់បានទទួលគ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលីក ៤២គ្រាប់ បន្ទាប់ពីសម្រាល | | |
| គ្រប់ម្តាយទាំងអស់ត្រូវបានផ្តល់គ្រាប់ថ្នាំជីវជាតិអាលេខ២០០,០០០IUភ្លាមៗក្រោយពីសម្រាលតាមតែអាចធ្វើទៅបាន | | |
| គ្រប់ម្តាយទាំងអស់ត្រូវបានផ្តល់ថ្នាំទំលាក់ព្រូនពោះវៀន (មេបង់ដាសុល៥០០មក្រ) ភ្លាមៗបន្ទាប់ពីសម្រាលតាមតែអាចធ្វើទៅបាន | | |
| ទារកទើបកើតទទួលវ៉ាក់សាំងការពារជំងឺរបេង និងជំងឺរលាកថ្លើមប្រភេទបេភ្លាមៗតាមតែអាចធ្វើទៅបានបន្ទាប់ពីសម្រាល | | |
| គ្រប់ម្តាយទាំងអស់បានទទួលព័ត៌មានពីការបរិភោគអាហារបន្ថែមមួយពេលរាល់ថ្ងៃនៅពេលដែលគាត់បំបៅកូនដោយទឹកដោះម្តាយ | | |
| គ្រប់ម្តាយទាំងអស់បានទទួលព័ត៌មានពីអាហារូបត្ថម្ភដែលល្អសំរាប់សុខភាព និងរបបអាហារផ្សេងៗ | | |
| សរុប | | |

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្ត្រសកម្មភាព |
|---|---|---|
| ៣- ការជួបពិនិត្យផ្ទៃទាំកុមារឈឺ និងកុមារមានសុខភាពល្អ | | |
| កុមារទាំងអស់បានវាយតម្លៃពីបញ្ហាសុខភាព និងធ្វើការព្យាបាលទៅតាមគោលការណ៍ IMCI (រំលងប្រសិនបើមិនទាន់បានទទួលការបណ្តុះបណ្តាល) | | |
| គ្រប់កុមារទាំងអស់ត្រូវបានពិនិត្យពីស្ថានភាពការទទួលថ្នាំបង្ការ ហើយផ្តល់ថ្នាំបង្ការ បើសិនជាចាំបាច់ | | |
| គ្រប់កុមារទាំងអស់ដែលមកមណ្ឌលសុខភាពត្រូវបានថ្លឹងទំងន់ ហើយទំងន់របស់ពួកគេត្រូវបានកត់ត្រានៅលើប័ណ្ណលឿង | | |
| គ្រប់ឪពុកម្តាយទាំងអស់បានទទួលការផ្តល់ប្រឹក្សាអំពីការអនុវត្តន៍ ការផ្តល់អាហារបន្ថែមដ៏សមស្រប | | |
| កុមារដែលមានបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ | | |
| គ្រប់កុមារទាំងអស់ត្រូវបានពិនិត្យរកភាពស្លេកស្លាំង និងធ្វើការព្យាបាល | | |
| គ្រប់កុមារទាំងអស់ត្រូវបានពិនិត្យរកបញ្ហាកង្វះជីវជាតិអា និងធ្វើការព្យាបាលទៅតាមគោលការណ៍ថ្នាក់ជាតិ | | |
| សរុប | | |
| ៤- ការចុះមូលដ្ឋាន | | |
| ការចុះមូលដ្ឋានត្រូវបានធ្វើឡើងជាទៀងទាត់ទៅតាមផែនការ | | |
| ព័ត៌មានត្រូវបានផ្តល់ជាមុនទៅឱ្យប្រធានភូមិ និងអ្នកស្ម័គ្រចិត្ត | | |
| អ្នកស្ម័គ្រចិត្តបានធ្វើបច្ចុប្បន្នភាពបញ្ជីកុមារអាយុ 0-៥ឆ្នាំ និងស្ត្រីមានផ្ទៃពោះ | | |
| សំភារៈ និងការផ្គត់ផ្គង់ (វ៉ាក់សាំង គ្រាប់ថ្នាំជីវជាតិអាជាតិដែក មេបង់ដាសុល ថ្នាំពន្យាកំណើត) តែងតែមានសំរាប់សកម្មភាពចុះមូលដ្ឋាន | | |
| សន្លឹកកត់ត្រាត្រូវបានរៀបចំទុកជាមុន និងត្រូវបានយកទៅប្រើប្រាស់ក្នុងពេលចុះមូលដ្ឋាន | | |

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្រ្តសកម្មភាព |
|---|---|---|
| សេវា/គ្រាប់ថ្នាំដែលបានផ្ដល់ត្រូវបានកត់ត្រានៅលើសៀវភៅសុខភាពមាតា/ប័ណ្ណសុខភាពកុមារ | | |
| អ្នកស្ម័គ្រចិត្តភូមិបានចូលរួមក្នុងសកម្មភាពចុះមូលដ្ឋាន | | |
| សរុប | | |
| ៥- ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអាពីរដងក្នុងមួយឆ្នាំ | | |
| រៀបចំ ៣ខែមុនជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| ចំនួនកុមារនិងម្ដាយដែលសបស្របនឹងទទួលគ្រាប់ថ្នាំជីវជាតិ អា និងមេបង់ដាសុលត្រូវបានធ្វើការប៉ាន់ប្រមាណ | | |
| ពិនិត្យមើលគុណភាព ការផុតកាលបរិច្ឆេទប្រើ និងចំនួននៃស្តុកគ្រាប់ថ្នាំជីវជាតិអា និងមេបង់ដាសុល | | |
| គ្រាប់ថ្នាំជីវជាតិអា និងគ្រាប់ថ្នាំមេបង់ដាសុលត្រូវបានស្នើរសុំតាមតំរូវការ | | |
| ការរៀបចំ ១ខែមុនជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| ធ្វើផែនការប្រជុំជាមួយអ្នកស្ម័គ្រចិត្តភូមិ | | |
| ផ្ដល់ដំណឹងទៅប្រធានភូមិ និងអ្នកស្ម័គ្រចិត្តសុខភាពភូមិពីកាលវិភាគសំរាប់ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| សំភារៈអប់រំត្រូវបានចែកចាយ | | |
| សន្លឹកកត់ត្រាត្រូវបានរៀបចំសំរាប់ភូមិនីមួយៗ | | |
| បញ្ជីកត់ត្រារបស់អ្នកស្ម័គ្រចិត្តភូមិត្រូវបានធ្វើបច្ចុប្បន្នភាព | | |
| នៅថ្ងៃចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| អ្នកស្ម័គ្រចិត្តភូមិ និងប្រធានភូមិជួយក្នុងការចលនាប្រជាជន | | |
| អ្នកស្ម័គ្រចិត្តភូមិចូលរួម និងផ្ដល់ការអប់រំសុខភាព | | |
| គ្រាប់ថ្នាំជីវជាតិអា និងមេបង់ដាសុលត្រូវបានកត់ត្រានៅលើប័ណ្ណសុខភាពកុមារ បញ្ជីចុះឈ្មោះរបស់អ្នកស្ម័គ្រចិត្ត និងសន្លឹកកត់ត្រា | | |
| បន្ទាប់ពីជុំចែកចាយភ្លាមៗ | | |
| ពិនិត្យបញ្ជីចុះឈ្មោះរបស់អ្នកស្ម័គ្រចិត្តដើម្បីរកមើលកុមារដែលមិនបានមក | | |

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្រ្តសកម្មភាព |
|---|---|---|
| សកម្មភាពបោសសំអាតត្រូវបានធ្វើផែនការជាមួយអ្នកស្ម័គ្រចិត្ត | | |
| ផ្តល់គ្រាប់ថ្នាំជីវជាតិអា និងមេបង់ដាសុលតាមតំរូវការទៅឱ្យអ្នកស្ម័គ្រចិត្តភូមិ | | |
| សកម្មភាពបោសសំអាតត្រូវបានរាយការណ៍ទៅឱ្យបុគ្គលិកមណ្ឌលសុខភាពដោយអ្នកស្ម័គ្រចិត្ត | | |
| ទិន្នន័យនៃសន្លឹកកត់ត្រាត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ HIS | | |
| ពិភាក្សាការគ្របដណ្តប់ជីវជាតិអាជាមួយបុគ្គលិកមណ្ឌលសុខភាព និងអ្នកស្ម័គ្រចិត្តភូមិ | | |
| សរុប | | |
| ៦- ការគ្រប់គ្រងស្តុកមីក្រូសារជាតិ | | |
| ធ្វើបញ្ជីសារពើនៃស្តុកគ្រាប់ថ្នាំជីវជាតិអាមេបង់ដាសុល និងជាតិដែក រាល់បីខែម្តង | | |
| ឱសថដែលហួសកំណត់កាលបរិច្ឆេទប្រើ ត្រូវបានផ្តល់ព័ត៌មានទៅស្រុកប្រតិបត្តិ | | |
| ស្តុកមីក្រូសារជាតិត្រូវបានស្នើរសុំទាន់ពេលវេលា | | |
| ឱសថដែលបានស្នើសុំត្រូវបានផ្តល់ឱ្យទាន់ពេល ដោយស្រុកប្រតិបត្តិ | | |
| សរុប | | |
| ៧- ការគ្រប់គ្រងទិន្នន័យប្រព័ន្ធព័ត៌មានសុខាភិបាល | | |
| បំពេញរបាយការណ៍ប្រព័ន្ធព័ត៌មានសុខាភិបាលប្រចាំខែ និងបញ្ជូនទៅឱ្យស្រុកប្រតិបត្តិទាន់ពេល | | |
| របាយការណ៍ប្រព័ន្ធព័ត៌មានសុខាភិបាល ត្រូវបានពិនិត្យមើលដោយប្រធានមណ្ឌលសុខភាព ហើយរាល់បញ្ហាដែលមានត្រូវបានតាមដានភ្លាមៗ | | |
| សន្លឹកកត់ត្រាត្រូវបានថតចំលង និងរក្សាទុកនៅមណ្ឌលសុខភាព | | |
| មណ្ឌលសុខភាពបានកំណត់គោលដៅសំរាប់ការគ្របដណ្តប់គ្រាប់ថ្នាំជីវជាតិអា | | |

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្ត្រសកម្មភាព |
|---|---|---|
| មណ្ឌលសុខភាពបានកំណត់គោលដៅសំរាប់ការគ្រប ដណ្តប់ថ្នាំជាតិដែក | | |
| មណ្ឌលសុខភាពបានកំណត់គោលដៅសំរាប់ការគ្រប ដណ្តប់គ្រាប់ថ្នាំមេបង់ដាសុល | | |
| សរុប | | |
| ៨- ការធ្វើតេស្តអំបិល | | |
| មានឃីតសំរាប់ធ្វើតេស្តអំបិល | | |
| ការធ្វើតេស្តអំបិលធ្វើឡើងដោយបុគ្គលិកសុខាភិបាល | | |
| លទ្ធផលនៃការធ្វើតេស្តត្រូវបានរាយការណ៍ជូនទៅ ប្រធានភូមិ | | |
| វិធានការណ៍ចាំបាច់ត្រូវបានពិភាក្សាជាមួយប្រធានភូមិ | | |
| លទ្ធផលត្រូវបានរាយការណ៍ទៅឱ្យស្រុកប្រតិបត្តិ | | |
| សរុប | | |
| ៩- ព្រឹត្តិការណ៍អាហារូបត្ថម្ភសំខាន់ៗ | | |
| ប្រជុំធ្វើផែនការជាមួយសហគមន៍ និងអ្នកស្ម័គ្រចិត្តពី ព្រឹត្តិការណ៍សំខាន់ៗ ដូចជា សប្តាហ៍ការបំបៅកូនដោយទឹកដោះម្តាយ | | |
| ព្រឹត្តិការណ៍ផ្សេងៗទៀត | | |
| សំភារៈអប់រំត្រូវបានចែកចាយទៅអ្នកភូមិ | | |
| សរុប | | |
| ពិន្ទុសរុប | | |
| ការដាក់ពិន្ទុ : 0= មិនគ្រប់គ្រាន់, ១=មធ្យម , ២ = ល្អ , ៣ = ល្អណាស់ , ៤ = ល្អឥតខ្ចោះ | | |

## ការតាមដានផែនការសកម្មភាព

| កាលបរិច្ឆេទ | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ហត្ថលេខាអ្នកអភិបាល |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

# ឧបករណ៍វាយតម្លៃខ្លួនឯងសំរាប់
# អ្នកស្ម័គ្រចិត្តភូមិ

ឧបករណ៍វាយតម្លៃខ្លួនឯងនេះនឹងត្រូវយកមកប្រើក្នុងពេលប្រជុំអ្នកស្ម័គ្រចិត្តនៅថ្នាក់មណ្ឌលសុខភាព

### របៀបប្រើប្រាស់ឧបករណ៍នេះ

### ១- បុគ្គលិកមណ្ឌលសុខភាពណែនាំពីឧបករណ៍វាយតម្លៃខ្លួនឯងនេះដល់អ្នកស្ម័គ្រចិត្ត

ឧបរណ៍វាយតម្លៃនេះផ្តល់ឱកាសដល់អ្នកស្ម័គ្រចិត្ត និងបុគ្គលិកមណ្ឌលសុខភាពកំណត់រកសកម្មភាពអាហារូបត្ថម្ភមានដំណើរការល្អនៅក្នុងតំបន់គ្រប់ដណ្តប់របស់គាត់ និងសកម្មភាពចាំបាច់ត្រូវពង្រឹងបន្ថែម។ ឧបករណ៍នេះក៏ផ្តល់ឱកាសដល់ក្រុមឱ្យធ្វើការជាមួយគ្នាក្នុងការកំណត់រកមធ្យោបាយដើម្បីពង្រឹងសកម្មភាពទាំងឡាយ និងឯកភាពគ្នាលើវិធានការណ៍ដែលនឹងយកមកអនុវត្ត។

អ្នកស្ម័គ្រចិត្តនឹងធ្វើការជាបុគ្គលក្នុងការបំពេញទំរង់នេះ ហើយបន្ទាប់មកប្រើទំរង់នេះដើម្បីធ្វើការពិភាក្សាជាក្រុមធំជាមួយអ្នកស្ម័គ្រចិត្តផ្សេងទៀត និងបុគ្គលិកមណ្ឌលសុខភាព។

**កំណត់សំគាល់: ប្រសិនបើអ្នកស្ម័គ្រចិត្តមិនចេះអានទេ បុគ្គលិកសុខាភិបាលអាចអានមួយចំណុចម្តងៗនៅក្នុងទំរង់វាយតម្លៃនេះ និងបំពេញវាទៅតាមការផ្តល់ព័ត៌មានត្រលប់របស់អ្នកស្ម័គ្រចិត្តភូមិ។**

### ២- បុគ្គលិកមណ្ឌលសុខភាពបង្ហាញ និងពន្យល់ពីទំរង់វាយតម្លៃខ្លួនឯងនេះ។ ផ្តល់ទំរង់នេះទៅឱ្យអ្នកស្ម័គ្រចិត្ត។

ឧបករណ៍វាយតម្លៃខ្លួនឯងនេះចែកចេញជាបីកូលោន :

កូលោនទីមួយ គឺជាសកម្មភាពអាហារូបត្ថម្ភនៅក្នុងការជួបនីមួយៗ។

កូលោនទីពីរ គឺឱ្យអ្នក (អ្នកស្ម័គ្រចិត្ត) ដាក់ពិន្ទុខ្លួនឯង។ ការដាក់ពិន្ទុត្រូវបានបែងចែកដូចតទៅ :

- ០= មិនគ្រប់គ្រាន់
- ១= មធ្យម
- ២ = ល្អ
- ៣ = ល្អណាស់
- ៤ = ល្អឥតខ្ចោះ

នៅក្នុងផ្នែកនីមួយៗ សូមដាក់ពិន្ទុគ្រប់ចំណុចទាំងអស់ដែលបានរៀបរាប់នៅក្នុងផ្នែកនីមួយៗ ហើយបូកពិន្ទុទាំងនោះចូលគ្នាដើម្បីបានពិន្ទុសរុបសំរាប់ផ្នែកនីមួយៗ។ នៅចុងបញ្ចប់បូកសរុបពិន្ទុសរុបនៃផ្នែកនីមួយៗ ដើម្បីបានពិន្ទុសរុបរួម។

កូលោនទីបី គឺឱ្យអ្នកកំណត់រកសកម្មភាពត្រូវធ្វើបន្ត។ កំណត់រក ប្រធានបទដែលមានពិន្ទុទាបជាងគេ។

នៅពេលដែលទំរង់វាយតម្លៃខ្លួនឯងនេះបានបំពេញចប់សព្វគ្រប់ហើយសូមធ្វើការពិភាក្សាលទ្ធផលជាក្រុមធំ។ ធ្វើការសរសើរលើសកម្មភាពដែលមានដំណើរការល្អ និងធ្វើការពិភាក្សាលើសកម្មភាពដែលមិនសូវបានល្អ។ កំណត់រកវិធានការណ៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវសកម្មភាពទាំងឡាយណាដែលមិនសូវល្អ។

បុគ្គលិកមណ្ឌលសុខភាព នឹងរក្សាកំណត់ហេតុនៃវិធានការណ៍ទាំងឡាយដែលបានផ្តល់ជាអនុសាសន៍ និងធ្វើការតាមដានលើវឌ្ឍនភាព ហើយនឹងធ្វើការពិភាក្សានៅអំឡុងពេលប្រជុំអ្នកស្ម័គ្រចិត្តលើកក្រោយ។ ការវាយតម្លៃខ្លួនឯងនេះអាចធ្វើពីរដងក្នុងមួយឆ្នាំ (បន្ទាប់ពីជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា)។

ពិន្ទុ : ០ = មិនគ្រប់គ្រាន់ ១ = មធ្យម ២ = ល្អ ៣ = ល្អណាស់ ៤ = ល្អឥតខ្ចោះ

ទំរង់វាយតម្លៃខ្លួនឯងសំរាប់អ្នកស្ម័គ្រចិត្តភូមិ

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្ត្រសកម្មភាព |
|---|---|---|
| ១- គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់នៅក្នុងភូមិខ្ញុំៈ | | |
| បានចុះបញ្ជីនៅក្នុងបញ្ជីភូមិ | | |
| បានទៅពិនិត្យផ្ទៃទាំផ្ទៃពោះមុនពេលសំរាល ៤ដងក្នុងអំឡុងពេលមានផ្ទៃពោះ | | |
| លេបគ្រាប់ថ្នាំជាតិដែក៩០គ្រាប់នៅក្នុងអំឡុងពេលមានផ្ទៃពោះ | | |
| បានទទួលថ្នាំទំលាក់ព្រូនពោះវៀនបន្ទាប់ពីខែទីបីនៃការមានផ្ទៃពោះ | | |
| បរិភោគអាហារបន្ថែមមួយពេលក្នុងមួយថ្ងៃនៅក្នុងអំឡុងពេលនៃការមានផ្ទៃពោះ | | |
| ស្គាល់ពីសញ្ញាគ្រោះថ្នាក់នៅពេលមានផ្ទៃពោះ | | |
| មានផែនការ និងត្រៀមសាហ៊ុយសំរាប់មធ្យោបាយធ្វើដំណើរសំរាប់ការសំរាល | | |
| បានទទួលព័ត៌មានពីការបំបៅដោះកូនដោយទឹកដោះម្តាយតែ១មុខគត់ និងការបំបៅកូនដោយទឹកដោះម្តាយឱ្យបានឆាប់បន្ទាប់ពីសំរាល | | |
| សរុប | | |
| ២- គ្រប់ស្ត្រីក្រោយសំរាល និងទារកទើបកើតនៅក្នុងភូមិខ្ញុំ : | | |
| បានចុះបញ្ជីនៅក្នុងបញ្ជីភូមិខ្ញុំ | | |
| គ្រប់ម្តាយទាំងអស់បានទទួលការគាំទ្រឱ្យដាក់ស្បែកប៉ះស្បែក | | |
| គ្រប់ម្តាយទាំងអស់បំបៅកូនដោយទឹកដោះម្តាយក្នុងម៉ោងដំបូងបន្ទាប់ពីសំរាល | | |
| គ្រប់ម្តាយទាំងអស់បានទទួលការផ្តល់ប្រឹក្សាពីការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ក្នុងរយៈពេល៦ខែដំបូង | | |
| ម្តាយគ្រប់រូបត្រូវបានផ្តល់ប្រឹក្សាអំពីការបំបៅដោះកូនអោយអោយញឹកញាប់ទាំងយប់ និងថ្ងៃ | | |

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្ត្រសកម្មភាព |
| --- | --- | --- |
| គ្រប់ម្តាយទាំងអស់បានទទួលគ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិក ៤២ គ្រាប់ បន្ទាប់ពីសំរាល | | |
| គ្រប់ម្តាយទាំងអស់បានទទួលគ្រាប់ថ្នាំជីវជាតិ អា លេខ ២០០, ០០០ ភ្លាមបន្ទាប់ពីសំរាលនៅក្នុងចន្លោះ ៦សប្តាហ៍ដំបូង | | |
| គ្រប់ម្តាយទាំងអស់បានទទួលថ្នាំទំលាក់ព្រូន (មេបង់ដាសុល =៥០០មក្រ) បន្ទាប់ពីសំរាល | | |
| ទារកទើបកើតបានទទួលវ៉ាក់សាំងការពារជំងឺរបេង និងការពារជំងឺរលាកថ្លើមប្រភេទ បេ បន្ទាប់ពីកើតភ្លាម | | |
| គ្រប់ម្តាយទាំងអស់បានទទួលព័ត៌មានអំពីការបរិភោគអាហារបន្ថែមមួយពេលក្នុងមួយថ្ងៃនៅពេលដែលគាត់បំបៅកូនដោយទឹកដោះម្តាយ | | |
| គ្រប់ម្តាយទាំងអស់បានទទួលព័ត៌មានអំពី អាហារូបត្ថម្ភ និងប្រភេទអាហារផ្សេងៗ | | |
| សរុប | | |
| ៣- គ្រប់កុមារអាយុ ០-៥ ឆ្នាំនៅក្នុងភូមិខ្ញុំ : | | |
| បានចុះបញ្ជីនៅក្នុងបញ្ជីភូមិ | | |
| បំបៅដោះម្តាយតែមួយមុខគត់នៅក្នុងរយៈពេល៦ខែដំបូង | | |
| ម្តាយបានទទួលព័ត៌មានពីអាហារបន្ថែម ភាពទៀងទាត់ ប្រភេទផ្សេងៗគ្នា ចំនួន និងភាពញឹកញាប់ | | |
| ចាប់ផ្តើមទទួលអាហារបន្ថែមនៅអាយុ៦ខែ | | |
| កុមារគ្រប់រូបអាយុពី ៦-១១ខែ បានទទួលគ្រាប់ថ្នាំជីវជាតិអា លេខ ១០០,០០០ IU ពីរដងក្នុងមួយឆ្នាំ នៅជុំវិញខែឧសភា និងវិច្ឆិកា | | |
| គ្រប់កុមារអាយុ១២-៥៩ខែ បានទទួលថ្នាំគ្រាប់ជីវជាតិ អា លេខ ២០០,០០០ IU និងថ្នាំទម្លាក់ព្រូន ពីរដងក្នុង១ឆ្នាំ ក្នុងខែឧសភា និងវិច្ឆិកា | | |
| ម្តាយតែងតែយកប័ណ្ណសុខភាពកុមារទៅជាមួយ (ប័ណ្ណលឿង) ពេលទទួលសេវាចុះមូលដ្ឋាន និងពេលទៅមណ្ឌលសុខភាព | | |

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្រ្តសកម្មភាព |
|---|---|---|
| គ្រាប់ថ្នាំជីវជាតិអា និងថ្នាំទំលាក់ព្រូនត្រូវបានកត់ត្រានៅលើប័ណ្ណលឿងកុមារ | | |
| ម្តាយបានទទួលព័ត៌មានអំពីអាហារដែលសំបូរជីវជាតិអា ជាតិដែក និងអ៊ីយ៉ូដ | | |
| សរុប | | |
| ៤- ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា ពីរដងក្នុងមួយឆ្នាំ ជុំវិញខែឧសភា និងខែវិច្ឆិកា | | |
| មួយខែមុនជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| អ្នកស្ម័គ្រចិត្តភូមិបានចូលរួមប្រជុំជាមួយមណ្ឌលសុខភាព ដើម្បីធ្វើផែនការចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| បញ្ជីចុះឈ្មោះភូមិត្រូវបានធ្វើបច្ចុប្បន្នភាពមុនជុំចែកចាយ ហើយព័ត៌មានអំពីចំនួនកុមារត្រូវបានផ្តល់ទៅឱ្យបុគ្គលិកមណ្ឌលសុខភាព | | |
| ដំណឹងត្រូវបានផ្តល់ជូនទៅប្រធានភូមិ និងសហគមន៍ អំពីថ្ងៃ ពេលវេលា និងទីកន្លែងនៃការចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| នៅក្នុងអំឡុងពេលជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |
| បដា និងផ្ទាំងរូបភាពស្តីពីជីវជាតិអា ត្រូវបានដាក់តាំងនៅក្នុងភូមិ | | |
| ឪពុកម្តាយ និងអ្នកថែទាំបានទទួលព័ត៌មានអំពីសារៈសំខាន់នៃការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា | | |
| នៅថ្ងៃចែកចាយគ្រាប់ថ្នាំជីវជាតិអា អ្នកស្ម័គ្រចិត្តប្រាប់ម្តាយៗឱ្យយកកូនគាត់ទៅចូលរួម និងរំលឹកពួកគាត់ឱ្យយកប័ណ្ណលឿងទៅជាមួយ | | |
| អ្នកស្ម័គ្រចិត្តផ្តល់ព័ត៌មានអំពីជីវជាតិអា ឱ្យទៅម្តាយ | | |
| អ្នកស្ម័គ្រចិត្តកត់ត្រានៅលើបញ្ជីរបស់គាត់រាល់កុមារដែលបានទទួលគ្រាប់ថ្នាំជីវជាតិអា | | |
| សរុប | | |
| ៥- សកម្មភាពបោសសំអាតសំរាប់ការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា | | |
| នៅក្នុងភូមិខ្ញុំ បន្ទាប់ពីជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា | | |

| សកម្មភាពគន្លឹះ | ពិន្ទុ * | អនុសាស្រ្តសកម្មភាព |
| --- | --- | --- |
| អ្នកស្ម័គ្រចិត្តពិភាក្សាជាមួយបុគ្គលិកមណ្ឌលសុខភាពអំពីចំនួនកុមារដែលមិនបានមកទទួលគ្រាប់ថ្នាំជីវជាតិអា | | |
| បុគ្គលិកមណ្ឌលសុខភាព និងអ្នកស្ម័គ្រចិត្តធ្វើការប្រៀបធៀបសន្លឹកកត់ត្រា និងបញ្ជីឈ្មោះរបស់អ្នកស្ម័គ្រចិត្ត | | |
| អ្នកស្ម័គ្រចិត្តទទួលគ្រាប់ថ្នាំជីវជាតិអា និងថ្នាំទំលាក់ព្រូនដើម្បីយកទៅឱ្យកុមារដែលមិនបានមកទទួលនៅជុំចែកចាយ | | |
| អ្នកស្ម័គ្រចិត្តពន្យល់ម្ដាយអំពីជីវជាតិអា និងផ្ដល់គ្រាប់ថ្នាំជីវជាតិអា និងថ្នាំទំលាក់ព្រូនដល់កុមារ បើសិនកុមារមានអាយុ ១២-៥៩ឆ្នាំ | | |
| អ្នកស្ម័គ្រចិត្តកត់ត្រាលើប័ណ្ណលឿង និងបញ្ជីឈ្មោះចំពោះកុមារដែលទទួលគ្រាប់ថ្នាំជីវជាតិអា នៅពេលសកម្មភាពចុះមូលដ្ឋាននៅក្នុងភូមិ | | |
| អ្នកស្ម័គ្រចិត្តរាយការណ៍ប្រគល់គ្រាប់ថ្នាំជីវជាតិអា និងថ្នាំទំលាក់ព្រូន ដែលមិនបានប្រើទៅឱ្យបុគ្គលិកមណ្ឌលសុខភាពវិញ | | |
| សរុប | | |
| ៦- ការធ្វើតេស្តអំបិល | | |
| នៅក្នុងភូមិខ្ញុំ : | | |
| សមាជិកសហគមន៍បានទទួលព័ត៌មានអំពីជាតិអ៊ីយ៉ូដ និងអំបិលអ៊ីយ៉ូដ | | |
| អ្នកស្ម័គ្រចិត្តភូមិចូលរួមក្នុងការធ្វើតេស្តអំបិលដោយមានការណែនាំពីបុគ្គលិកមណ្ឌលសុខភាព និងផ្ដល់ព័ត៌មានទៅឱ្យសហគមន៍អំពីស្ថានភាពអំបិលនៅក្នុងសហគមន៍របស់ពួកគាត់ | | |
| អ្នកស្ម័គ្រចិត្តរាយការណ៍ទៅឱ្យប្រធានភូមិ និងបុគ្គលិកមណ្ឌលសុខភាពពីលទ្ធផលនៃការធ្វើតេស្តអំបិល | | |
| សរុប | | |
| ពិន្ទុសរុប | | |
| 0= មិនគ្រប់គ្រាន់, ១=មធ្យម , ២ = ល្អ , ៣ = ល្អណាស់ , ៤ = ល្អឥតខ្ចោះ | | |

## ការតាមដានផែនការសកម្មភាព

| កាលបរិច្ឆេទ | សកម្មភាពគន្លឹះ | អ្នកទទួលខុសត្រូវ | ហត្ថលេខាអ្នកអភិបាល |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |